ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សេចក្តីប្រកាសព័ត៌មាន

រាជធានីភ្នំពេញ៖ ថ្ងៃទី ២៨ ខែមីនា ២០១៤ ដោយ អគ្គនាយកដ្ឋានពន្ធដារ

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពីជំនួបពិភាក្សាការងារ
## រវាងឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និង
## ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ

នៅព្រឹកថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារបានដឹកនាំគណៈប្រតិភូជាន់ខ្ពស់ ចូលជួបធ្វើសវនការជាមួយឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងសហការី នៅទីស្តីការក្រសួងពាណិជ្ជកម្ម ដើម្បីពិភាក្សាការងារអំពីការចុះបញ្ជីសហគ្រាស ។

ជាកិច្ចចាប់ផ្តើម ឯកឧត្តមទេសរដ្ឋមន្ត្រី **ស៊ុន ចាន់ថុល** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានសម្តែងការស្វាគមន៍ យ៉ាងកក់ក្តៅ ចំពោះគណៈប្រតិភូជាន់ខ្ពស់នៃអគ្គនាយកដ្ឋានពន្ធដារ ដែលបានចូលជួបពិភាក្សាការងារនាវេលាព្រឹកនេះ ។



ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលបានសម្តែងនូវអំណរគុណចំពោះឯកឧត្តមទេសរដ្ឋមន្ត្រី ដែលបានអនុញ្ញាតឱ្យគណៈប្រតិភូរបស់អគ្គនាយកដ្ឋានពន្ធដារចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ ។ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល បានគោរពជម្រាបជូនឯកឧត្តមទេសរដ្ឋមន្ត្រី អំពីគោលបំណងដ៏សំខាន់នៃជំនួបពិភាក្សានាព្រឹកនេះ គឺដើម្បីលើកឡើងនូវបញ្ហាប្រឈមដែលនាំទៅដល់ហានិភ័យខ្ពស់ក្នុងការបាត់ចំណូលពន្ធ ដែលផ្តើមចេញពីកិច្ចការចុះបញ្ជី ។ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលបានបញ្ជាក់ជូនឯកឧត្តមទេសរដ្ឋមន្ត្រី ថា ក្នុងការជំរុញការអនុវត្តគោលនយោបាយកំណែទម្រង់ស៊ីជម្រៅដ៏មុតស្រួច និងការពង្រឹងអភិបាលកិច្ចល្អរបស់រាជរដ្ឋាភិបាលនីតិកាលទីប្រាំនៃរដ្ឋសភា អគ្គនាយកដ្ឋានបានចាប់យករបត់នៃការកែទម្រង់ថ្មីមួយ ដែលធ្វើឱ្យស្ថានភាពនៃការពង្រឹងគោលនយោបាយសារពើពន្ធ និងរដ្ឋបាលសារពើពន្ធ ត្រូវធ្វើការកែទម្រង់ផងដែរ ដែលក្នុងនោះ ការកែទម្រង់ការចុះបញ្ជីនៅអគ្គនាយកដ្ឋានពន្ធដារ គឺជាកិច្ចការដ៏ចម្បងមួយក្នុង ចំណោមកិច្ចការចម្បងៗទាំងឡាយ ។ ក្នុងរយៈពេលនៃការអនុវត្តការកែទម្រង់ការចុះបញ្ជីនេះ អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងជួបប្រទះ និងរកឃើញនូវចំណុចអសកម្មសំខាន់ៗមួយចំនួន ដូចខាងក្រោម ÷

១- ឈ្មោះអភិបាលសហគ្រាសដែលបានចុះបញ្ជី គឺជាតតិយជនដែលត្រូវបានសហគ្រាសធ្វើការក្លែងបន្លំឱ្យមកឈរឈ្មោះជំនួសម្ចាស់អាជីវកម្ម ដោយសាមីខ្លួនមិនបានដឹងទាល់តែសោះ ឬយកឈ្មោះមនុស្សដែលស្លាប់បាត់មកធ្វើជាម្ចាស់ក្រុមហ៊ុន ដើម្បីចុះបញ្ជីអាករលើតម្លៃបន្ថែមសម្រាប់ធ្វើការនាំចូល ហើយនៅពេលដែលអគ្គនាយកដ្ឋានពន្ធដារធ្វើការកំណត់ពន្ធ គឺមានតែឈ្មោះក្រុមហ៊ុនខ្មោចដែលមិនមានម្ចាស់ក្រុមហ៊ុនមកប្រកាសបង់ពន្ធ ។

២- ឈ្មោះអភិបាលសហគ្រាសដែលបានចុះបញ្ជី គឺជាបុគ្គលដែលត្រូវបានសហគ្រាសជួលឱ្យមកឈរឈ្មោះ ដោយសាមីខ្លួនមិនមានការយល់ដឹងពីកាតព្វកិច្ចសារពើពន្ធទាល់តែសោះ ដែលប្រការនេះគឺធ្វើឡើងក្នុងបំណងគេចវេះពីការបង់ពន្ធ ។




៣- សកម្មភាពអាជីវកម្មជាក់ស្តែងរបស់សហគ្រាស ផ្ទុយគ្នាស្រឡះពីសកម្មភាពដែលបានបញ្ជាក់ក្នុងពេលចុះបញ្ជី ។ ជាក់ស្តែង ដូចជាសហគ្រាសផ្តល់សេវាពិគ្រោះយោបល់ ប៉ុន្តែបែរជានាំចេញ-នាំចូលទំនិញ ក្នុងបំណងគេចវេះពន្ធ ។

៤- ព័ត៌មានស្តីពីអាសយដ្ឋានទំនាក់ទំនងរបស់សហគ្រាស មិនច្បាស់លាស់ ឬគ្មានទីតាំងពិតប្រាកដ ដែលប្រការនេះប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការកំណត់ពន្ធឡើងវិញរបស់អគ្គនាយកដ្ឋានពន្ធដារ ។

៥- និន្នាការចុះបញ្ជីក្រុមហ៊ុនដែលមានអភិបាលក្រុមហ៊ុនជាជនបរទេស ប៉ុន្តែទិដ្ឋាការលើលិខិតឆ្លងដែន ដែលផ្តល់ឱ្យគឺជាទិដ្ឋាការប្រភេទទេសចរណ៍រយៈពេលខ្លី ។

៦- សហគ្រាសមួយចំនួនជាសហគ្រាសខ្យល់ ដោយម្ចាស់សហគ្រាសស្នើចុះបញ្ជីគឺក្នុងគោលបំណងគ្រាន់តែធ្វើជាអំណះអំណាងសម្រាប់ការដាក់សម្ភាសន៍ទៅរស់នៅក្រៅប្រទេស ។

ជាការឆ្លើយតប ឯកឧត្តមទេសរដ្ឋមន្ត្រីបានទទួលស្គាល់នូវចំណុចខ្វះខាតនិងបញ្ហាប្រឈមដែលបានលើកឡើងដោយគណៈប្រតិភូរបស់អគ្គនាយកដ្ឋានពន្ធដារ ។ ឯកឧត្តមទេសរដ្ឋមន្ត្រីបានបញ្ជាក់បន្ថែមថា ការបង្កើតច្បាប់កម្មសិទ្ធិបញ្ញា និងការបង្កើតឡើងនូវបញ្ជរតែមួយ គឺជាយន្តការអាចជួយកាត់បន្ថយពេលវេលាក្នុងការចុះបញ្ជី ។ ទន្ទឹមនឹងនេះ ការសហការគ្នានៅមានកម្រិត ក្នុងដែនសមត្ថកិច្ចការងាររវាងអន្តរស្ថាប័ន ដែលជាចំណុចខ្វះចន្លោះ និងធ្វើឱ្យអ្នកជាប់ពន្ធឆ្លៀតឱកាសនេះដើម្បីលួចបន្លំ គេចវេះពន្ធ ។ ដើម្បីបង្កលក្ខណៈងាយស្រួល និងកាន់តែមានសុក្រឹតភាពលើកិច្ចការចុះបញ្ជីនេះ ក្រសួងពាណិជ្ជកម្មគ្រោងនឹងបង្កើតឱ្យមានការចុះបញ្ជីតាមប្រព័ន្ធអេឡិចត្រូនិច (E-Registration) និងរៀបចំនីតិវិធីចង្អុលបង្ហាញ (Process Mapping) អំពីដំណើរការចុះបញ្ជី ។

ជាលទ្ធផលនៃជំនួបពិភាក្សា ក្នុងគោលបំណងដើម្បីពង្រឹងយន្តការនៃការចុះបញ្ជីសហគ្រាសប្រព្រឹត្តទៅដោយរលូន និងមិនប្រឈមនឹងហានិភ័យខ្ពស់ សម្រាប់អគ្គនាយកដ្ឋានពន្ធដារក្នុងការចុះធ្វើសវនកម្ម ឯកឧត្តមទេសរដ្ឋមន្ត្រី និងឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល បានព្រមព្រៀងបង្កើតក្រុមការងារមួយដែលមានសមាសភាពពីទាំងពីរ ហើយដែលក្រុមការងារនេះ

មានកាតព្វកិច្ចស្វែងរកព័ត៌មានផ្លូវការដែលទាក់ទងនឹងសហគ្រាសពីក្រសួង-ស្ថាប័នពាក់ព័ន្ធ ដូចជា ធនាគារជាតិ ឬធនាគារឯកជននានា និងពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ជាដើម ។

ជំនួបពិភាក្សាការងារនេះ បានបញ្ចប់នៅវេលាម៉ោង ១១ និង៣០ នាទីព្រឹក នាថ្ងៃ ខែ ឆ្នាំដដែល ក្នុងបរិយាកាសស្និទ្ធស្នាល និងសហប្រតិបត្តិការខ្ពស់ ។

**អគ្គនាយកដ្ឋានពន្ធដារ**

**សំណូមពរ ÷**

១- ស្នើសុំបំពេញព័ត៌មានឲ្យបានគ្រប់គ្រាន់ និងច្បាស់លាស់ ទាក់ទងទៅនឹងសកម្មភាពអាជីវកម្មរបស់ សហគ្រាស អាសយដ្ឋានទំនាក់ទំនង និងព័ត៌មានពាក់ព័ន្ធនឹងបុគ្គលដែលឈរឈ្មោះជាអភិបាល សហគ្រាស ។

២- តភ្ជាប់បណ្តាញទិន្នន័យស្តីពីសហគ្រាស រវាងក្រសួងពាណិជ្ជកម្ម ជាមួយនិងអគ្គនាយកដ្ឋានពន្ធដារ ។

៣- ពង្រឹងការត្រួតពិនិត្យការចុះបញ្ជីសហគ្រាសដែលមានអភិបាលជាជនជាតិបរទេស ។

៤- បង្កើតក្រុមការងារអន្តរស្ថាប័ន រវាងក្រសួងពាណិជ្ជកម្ម និងអគ្គនាយកដ្ឋានពន្ធដារ ដើម្បីដោះស្រាយបញ្ហាប្រឈមបន្ទាន់ភ្លាមៗ ទាក់ទងនឹងការចុះបញ្ជី ជាពិសេស ការធ្វើបច្ចុប្បន្នភាពទិន្នន័យរបស់ សហគ្រាស ។